# បទបញ្ជាផ្ទៃក្នុង

# ព្រឹទ្ធសភា

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី ១
# អំពីការិយាល័យបណ្ដោះអាសន្ន និងការកិច្ច

ប្រការ ១ :

ព្រឹទ្ធសភាប្រជុំសាមញ្ញពីរដងក្នុងមួយឆ្នាំ ។

សម័យប្រជុំនីមួយៗមានថិរវេលាយ៉ាងតិចបីខែ ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្ដីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបីយ៉ាងតិច ព្រឹទ្ធសភាកោះប្រជុំជាវិសាមញ្ញ ។

ប្រការ ២ :

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូងរយៈពេល ៦០ ថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះអញ្ជើញរបស់ព្រះមហាក្សត្រ ។ ព្រះមហាក្សត្រ សម្ដេចព្រះរាជអគ្គមហេសី ឬព្រះរាជតំណាងប្រទាន ឬផ្ដល់កិត្តិយសចំពោះការបើកសម័យប្រជុំដំបូងនៃនីតិកាលនីមួយៗ។ នៅពេលបើកសម័យប្រជុំលើកទី ១ នៃនីតិកាលនីមួយៗ ព្រឹទ្ធសភាត្រូវចាប់ដំណើរការក្រោមអធិបតីភាពនៃប្រធានបណ្ដោះអាសន្នមួយរូប ដែលជាបេក្ខជនជាប់ឆ្នោតមានអាយុច្រើនជាងគេ ហើយដែលឥតមានបណ្ដឹងតវ៉ា ព្រមទាំងសមាជិក ៥ រូបដែលជាបេក្ខជនជាប់ឆ្នោត មានអាយុតិចជាងគេ និងឥតមានបណ្ដឹងតវ៉ា ជាលេខាធិការដើម្បីជួយការងារប្រធាន ។

ក្រោមការដឹកនាំរបស់ព្រឹទ្ធសមាជិកខាងលើ ព្រឹទ្ធសភាត្រូវចាប់ផ្ដើមការងារដូចតទៅ :

ក-ប្រកាសឈ្មោះសមាជិកព្រឹទ្ធសភាពេញសិទ្ធិ

ខ-ជ្រើសតាំងប្រធាន និងអនុប្រធានទាំងពីររបស់ព្រឹទ្ធសភា ។

ក្រោមអធិបតីភាពរបស់ព្រឹទ្ធសមាជិក ព្រឹទ្ធសភាមិនអាចជជែកពិភាក្សាអ្វីឡើយ ។

## ជំពូកទី ២
## អំពីសុពលភាពនៃសមាជិកព្រឹទ្ធសភា

ប្រការ ៣ :

នៅពេលបើកសម័យប្រជុំខាងលើនេះ ដើម្បីសំរេចអំពីសុពលភាព ព្រឹទ្ធសមាជិក ប្រកាសជូនអង្គសភា :

- ឈ្មោះបេក្ខជនជាប់ឆ្នោតជាស្ថាពរ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបញ្ជូនមក
- ឈ្មោះបេក្ខជនជាប់ឆ្នោតដែលមានបណ្តឹងតវ៉ា ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញបាន បដិសេធបណ្តឹងទាំងនោះ ។

សុពលភាពឈ្មោះសមាជិកព្រឹទ្ធសភាពេញសិទ្ធិទាំងនោះត្រូវបិទផ្សាយភ្លាមក្នុងព្រឹទ្ធសភា និងផ្សព្វផ្សាយជាសាធារណៈក្រោយពេលប្រជុំ ។

ប្រការ ៤ :

សមាជិកព្រឹទ្ធសភាមានឋានៈនិងបុព្វសិទ្ធិស្មើនឹងឧត្តមមន្ត្រីផុតលេខនៃព្រះរាជាណាចក្រ កម្ពុជា ។

# ជំពូកទី ៣
# អំពីប្រធាន អនុប្រធាន គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការនានានៃព្រឹទ្ធសភា

ប្រការ ៥ :

ក្រោយពីព្រះមហាក្សត្រ និងសម្តេចព្រះរាជអគ្គមហេសី ឬព្រះរាជតំណាង បានបើកនីតិកាលព្រឹទ្ធសភារួចហើយ បើព្រឹទ្ធសភាមានសមាជិកវត្តមានប្រាំពីរភាគដប់យ៉ាងតិចនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ព្រឹទ្ធសភាអាចដំណើរការបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន និងអនុប្រធានទាំងពីររបស់ខ្លួន ដោយមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ប្រការ ៦ :

ក្រោមអធិបតីភាពនៃប្រធានរបស់ខ្លួន ព្រឹទ្ធសភាចាប់ដំណើរការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

គណៈកម្មការនានានៃព្រឹទ្ធសភាមាន :

១-គណៈកម្មការការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹង

២-គណៈកម្មការហិរញ្ញវត្ថុ និងធនាគារ

៣-គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទនិងបរិស្ថាន

៤-គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត និងបោសសំអាត

៥-គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការនិងពត៌មាន

៦-គណៈកម្មការនីតិកម្ម

៧-គណៈកម្មការអប់រំ ធម្មការ វប្បធម៌ និងទេសចរណ៍

៨-គណៈកម្មការសុខាភិបាល សង្គមកិច្ច ការងារ និងកិច្ចការនារី

៩-គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពល និងពាណិជ្ជកម្ម ។

ប្រការ ៧ :

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាមាន :

-ប្រធានព្រឹទ្ធសភា

-អនុប្រធានទាំងពីរនៃព្រឹទ្ធសភា

-ប្រធានគណៈកម្មការនានានៃព្រឹទ្ធសភា

ប្រធានព្រឹទ្ធសភាជាប្រធាននៃគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាមានអាណត្តិស្មើនឹងនីតិកាលរបស់ព្រឹទ្ធសភា ។

ប្រការ ៨ :

ប្រធានព្រឹទ្ធសភាមានភារកិច្ចដូចតទៅ :

ក-ធានាការប្រព្រឹត្តទៅនៃព្រឹទ្ធសភាអោយបានត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ

ខ-ដឹកនាំអង្គប្រជុំនៃព្រឹទ្ធសភា និងគណៈកម្មាធិការអចិន្ត្រៃយ៍

គ-បើក ឬលើកពេលប្រជុំព្រឹទ្ធសភា និងគណៈកម្មាធិការអចិន្ត្រៃយ៍

ឃ-ចាត់ចែងការពិភាក្សា ហើយចុះហត្ថលេខាលើកំណត់ហេតុនៃការប្រជុំព្រឹទ្ធសភា

ង-ញ៉ាំងអោយប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

ច-រក្សាការពារសណ្តាប់ធ្នាប់ក្នុងព្រឹទ្ធសភា

ឆ-តំណាងព្រឹទ្ធសភាក្នុងការទាក់ទងជាមួយព្រះមហាក្សត្រ រដ្ឋសភាឬអាជ្ញាធរសាធារណៈ ។

ជ-ទាក់ទងជាមួយប្រធានរដ្ឋសភាដើម្បីរៀបចំសមាជអង្គសភាទាំងមូល ។

ប្រការ ៩ :

អនុប្រធានទាំងពីរជួយធ្វើការប្រធាន ។ កាលបើប្រធានអវត្តមាន ឬមកធ្វើការពុំបាន អនុប្រធានធ្វើការជំនួសប្រធាន ។

ប្រការ ១០ :

គណៈកម្មការនីមួយ ៗ ត្រូវជ្រើសតាំងប្រធានមួយរូប អនុប្រធានមួយរូប និងលេខាធិការមួយរូបដោយវិធីបោះឆ្នោត ។

គណៈកម្មការនីមួយៗមានសមាជិកយ៉ាងតិច ៥ រូប ។

កូរ៉ុមសំរាប់ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ឬគណៈកម្មការនានាត្រូវមានលើសពីពាក់កណ្ដាលនៃចំនួនសមាជិកទាំងមូល ។

រាល់ការសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការនានា ត្រូវអនុម័តដោយសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកទាំងមូល ។

<u>ប្រការ ១១</u> :

ក្នុងករណីចាំបាច់ ព្រឹទ្ធសភាអាចអនុម័តដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ក្នុងការសំរេចបង្កើតគណៈកម្មការពិសេសដែលមានសមាជិកច្រើនឬតិចតាមតម្រូវការ ។

<u>ប្រការ ១២</u> :

គណៈកម្មការនីមួយៗអាចស្នើសុំប្រធានព្រឹទ្ធសភាចាត់តាំងអ្នកជំនាញ ដែលមិនមែនជាសមាជិកព្រឹទ្ធសភា អោយចូលរួមធ្វើការបាន ។ អ្នកជំនាញនោះគ្មានសិទ្ធិសំរេចកិច្ចការរបស់គណៈកម្មការទេ ។

គណៈកម្មការនីមួយៗត្រូវកំណត់តួនាទី សមត្ថកិច្ច និងភារកិច្ចរបស់ខ្លួនអោយស្របទៅនឹងរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា និងច្បាប់ជាធរមានរបស់រដ្ឋ រួចដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យ និងសំរេច ។

<u>ប្រការ ១៣</u> :

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាមានភារកិច្ចដូចតទៅ

-ចាត់ចែងការងាររបស់ព្រឹទ្ធសភាក្នុងចន្លោះសម័យប្រជុំព្រឹទ្ធសភា

-រៀបចំរបៀបវារៈនៅពេលប្រជុំព្រឹទ្ធសភានីមួយៗ

-ធានាការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន

-លើកជូនព្រឹទ្ធសភាពិនិត្យនិងសំរេចលើការចោទប្រកាន់ ការចាប់ខ្លួន ការឃុំខ្លួន ការឃាត់ខ្លួន ដែលពាក់ព័ន្ធដល់ការដោះចាកសមាជិកភាពរបស់សមាជិកព្រឹទ្ធសភា ឬបញ្ហាលើកអភ័យឯកសិទ្ធិរបស់សមាជិកព្រឹទ្ធសភាណាមួយ ។

ក្នុងករណីដែលប្រធានគណៈកម្មការណាមួយអវត្តមាន អនុប្រធាន ឬលេខាធិការគណៈកម្មការនោះ មានសិទ្ធិចូលរួមប្រជុំក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ជំនួស ប៉ុន្តែពុំមានសិទ្ធិសំរេចការងារផ្សេងៗក្នុងនាមប្រធានបានឡើយ ។

<u>ប្រការ ១៤</u> :

សមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការនានារបស់ព្រឹទ្ធសភាដែលខានមកប្រជុំដោយឥតជូនដំណឹង ត្រូវទទួលទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងប្រការ៦៧និង៦៨ ។

## ជំពូកទី ៤
## អំពីអគ្គលេខាធិការដ្ឋាន

### ប្រការ ១៥ :

ព្រឹទ្ធសភាមានអគ្គលេខាធិការដ្ឋានមួយសំរាប់ទទួលបន្ទុកធ្វើកំណត់ហេតុរបស់ព្រឹទ្ធសភា របស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងរបស់គណៈកម្មការនានា ។ លើសពីនេះអគ្គលេខាធិការដ្ឋានទទួលរ៉ាប់រងរាល់កិច្ចការរដ្ឋបាលរបស់ព្រឹទ្ធសភា ព្រមទាំងទំនាក់ទំនងផ្សេងៗក្រៅព្រឹទ្ធសភា ។

### ប្រការ ១៦ :

អគ្គលេខាធិការដ្ឋានត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងមានអគ្គលេខាធិការរងមួយរូបជាជំនួយការ ។

អគ្គលេខាធិការនិងអគ្គលេខាធិការរងត្រូវជ្រើសតាំងក្នុងចំណោមមន្ត្រីជាន់ខ្ពស់ដែលមានបទពិសោធន៍ក្នុងកិច្ចការរដ្ឋបាលយ៉ាងតិច ១០ ឆ្នាំ ហើយដែលមិនមែនជាសមាជិកព្រឹទ្ធសភា និងមិនមែនជាអ្នកដឹកនាំគណបក្សនយោបាយ ។

### ប្រការ ១៧ :

អគ្គលេខាធិការនិងអគ្គលេខាធិការរងត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសេចក្តីស្នើរបស់ប្រធានព្រឹទ្ធសភា ក្រោយពីបានឯកភាពជាមួយអនុប្រធានទី១ និងអនុប្រធានទី២ ។

អគ្គលេខាធិការនិងអគ្គលេខាធិការរង មានឋានៈស្មើនឹងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ ។

### ប្រការ ១៨ :

បុគ្គលិកនៃអគ្គលេខាធិការដ្ឋានទាំងអស់ ត្រូវតែងតាំងដោយប្រធានព្រឹទ្ធសភាតាមសេចក្តីស្នើរបស់អគ្គលេខាធិការ ។

ប្រការ ១៩ :

អគ្គលេខាធិការដ្ឋានត្រូវកសាងឧបសម្ព័ន្ធមួយស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលក្ខន្តិកៈនៃមន្ត្រី បុគ្គលិកអគ្គលេខាធិការដ្ឋាន ដើម្បីដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍អនុម័ត និងយកទៅអនុវត្ត ។

ប្រការ ២០ :

កំណត់ហេតុទាំងអស់ និងឯកសារផ្សេងទៀតរបស់ព្រឹទ្ធសភាត្រូវរក្សាទុកនៅក្នុងអគ្គលេខាធិការដ្ឋាន ហើយមិនត្រូវធ្វើអោយបែកធ្លាយទៅខាងក្រៅ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីប្រធានឡើយ ។

## ជំពូកទី ៥
## អំពីរបៀបវារៈ

ប្រការ ២១ :

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ជាអ្នករៀបចំរបៀបវារៈនៃអង្គប្រជុំនីមួយៗ ។ នៅចុងបញ្ចប់នៃពេលប្រជុំ ប្រធានត្រូវអានរបៀបវារៈសម្រាប់អង្គប្រជុំបន្ត ។

ប្រការ ២២ :

របៀបវារៈមានជាលំដាប់មុនក្រោយដូចតទៅ :

១-បញ្ហាទាំងឡាយដែលព្រឹទ្ធសភាបានសំរេចថាទុកជាការប្រញាប់
២-បញ្ហាទាំងឡាយដែលរដ្ឋសភាជូនមកព្រឹទ្ធសភា
៣-បញ្ហាទាំងឡាយដែលរាជរដ្ឋាភិបាលជូនមកព្រឹទ្ធសភា
៤-បញ្ហាទាំងឡាយដែលគណៈកម្មការនានាជូនមកព្រឹទ្ធសភា
៥-បញ្ហាទាំងឡាយដែលសមាជិកព្រឹទ្ធសភាជូនមកព្រឹទ្ធសភា ។

## ជំពូកទី ៦
## អំពីសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ និងការពិនិត្យបញ្ហានានា

ប្រការ ២៣ :

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងបញ្ហានានាដែលរដ្ឋសភាបានដាក់អោយពិនិត្យ ត្រូវបញ្ជូនមកគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។ សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហានានានោះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយចែកជូនសមាជិកព្រឹទ្ធសភាទាំងអស់ ដោយភ្ជាប់សេចក្តីថ្លែងហេតុមកជាមួយផង ។

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហានានានោះ ទៅអោយគណៈកម្មការជំនាញពិនិត្យ ។ កាលបើពិនិត្យរួចហើយ ប្រធានគណៈកម្មការនោះ ត្រូវនាំយកយោបល់របស់គណៈកម្មការមកជំរាបជូនព្រឹទ្ធសភា ។

ប្រការ ២៤ :

សេចក្តីស្នើច្បាប់ដែលសមាជិកព្រឹទ្ធសភាជាអ្នកធ្វើ ត្រូវសរសេរជាលាយលក្ខណ៍អក្សរចែកជាមាត្រា ដោយមានភ្ជាប់សេចក្តីថ្លែងហេតុមកជាមួយ ។ សេចក្តីស្នើច្បាប់នេះត្រូវបញ្ជូនទៅរដ្ឋសភាតាមរយៈគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាក្រោយពីបានដាក់អោយគណៈកម្មការជំនាញព្រឹទ្ធសភាផ្តល់យោបល់ ។

ប្រការ ២៥ :

អ្នកតែងសេចក្តីស្នើច្បាប់មានសិទ្ធិចូលរាយការណ៍និងការពារចំពោះមុខគណៈកម្មការដែលពិនិត្យសេចក្តីស្នើនោះ ។

ប្រការ ២៦ :

គណៈកម្មការដែលបានទទួលពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តជាលើកដំបូង ឬបញ្ហានានា អាចសុំអោយព្រឹទ្ធសភា :

- លើកចោលពុំពិចារណា

- បញ្ចេញមតិជាមុនថា តើគួរពិចារណាឬមិនគួរ ?
- ទទួលពិចារណាហើយនឹងទុកជាការប្រញាប់ផងក៏បាន ។

ប្រការ ២៧ :

អ្នកតែងសេចក្តីស្នើច្បាប់ ឬអ្នកលើកបញ្ហានានា អាចដកសេចក្តីស្នើ ឬបញ្ហានានានោះចេញបាន ទោះបីព្រឹទ្ធសភាចាប់ពិភាក្សាហើយក៏ដោយ ។ ចំពោះសេចក្តីស្នើ ឬបញ្ហានានាដែលដកចេញ សមាជិកឯទៀតអាចសុំអោយព្រឹទ្ធសភាពិភាក្សាវិញបាន ។

## ជំពូកទី ៧
## អំពីការពិភាក្សាលើសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់

ប្រការ ២៨ :

សមាជិកព្រឹទ្ធសភាគ្រប់រូបអាចស្នើសុំធ្វើការកែសម្រួលលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ជាលាយលក្ខណ៍អក្សរ ជូនទៅគណៈកម្មការជំនាញក៏បាន ឬជូនទៅព្រឹទ្ធសភាក្នុងសម័យប្រជុំពេញអង្គក៏បាន ។

ប្រការ ២៩ :

ព្រឹទ្ធសភាអាចសំរេចយល់ព្រមឬមិនយល់ព្រមយកពាក្យសុំនោះមកពិភាក្សា ។

ប្រការ ៣០ :

ព្រឹទ្ធសភាមិនអនុម័តលើការកែសម្រួលក្នុងថ្ងៃដែលទទួលពាក្យសុំនោះទេ វៀរលែងតែជាការប្រញាប់ ។

ប្រការ ៣១ :

ការពិភាក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ត្រូវធ្វើដូចតទៅ :

១-អង្គប្រជុំព្រឹទ្ធសភាពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូល គឺបញ្ចេញមតិថាតើគួរពិចារណាឬទេ ។

២-អង្គប្រជុំព្រឹទ្ធសភានឹងអនុម័តលើមាត្រាមួយម្តងៗក៏បាន ឬលើជំពូកមួយម្តងៗក៏បាន ។

អង្គប្រជុំព្រឹទ្ធសភាអាចប្រើនីតិវិធីពិភាក្សាសង្ខេបបាន ដោយពិភាក្សាតែមាត្រា ឬជំពូកណាដែលមានសំណើធ្វើការកែសម្រួលជាលាយលក្ខណ៍អក្សរដូចមានចែងក្នុងប្រការទាំងឡាយខាងលើ ។

ក្នុងករណីដែលប្រើនីតិវិធីណាមួយខាងលើ គណៈកម្មាធិការអចិន្ត្រៃយ៍ត្រូវជូនពត៌មានដល់សមាជិកព្រឹទ្ធសភា ។

៣-ព្រឹទ្ធសភាអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំងមូល ។

## ជំពូកទី ៨
## ទំព័រទិកាព្រឹទ្ធសភា

ប្រការ ៣២ :

ព្រឹទ្ធសភាមានថវិកាស្វយ័តសំរាប់ដំណើរការរបស់ខ្លួន ។ សេចក្តីស្នើថវិការបស់ព្រឹទ្ធសភា ត្រូវកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ហើយបញ្ជូនទៅក្រសួងមានសមត្ថកិច្ចដើម្បីបញ្ចូលគម្រោងក្នុងថវិកាជាតិ ។

# ជំពូកទី ៩
## អំពីការបញ្ចេញមតិ

<u>ប្រការ ៣៣</u> :

ក្នុងបញ្ហាទាំងឡាយដែលព្រឹទ្ធសភាត្រូវពិនិត្យ ព្រឹទ្ធសភាបញ្ចេញមតិដោយវិធីបីយ៉ាង គឺ :

-ដោយលើកដៃ

-ដោយបោះឆ្នោតចំហ ឬ

-ដោយបោះឆ្នោតសម្ងាត់ ។

<u>ប្រការ ៣៤</u> :

ចំពោះការបញ្ចេញមតិដោយវិធីលើកដៃ ប្រធាននិងលេខាធិការទាំងឡាយជាអ្នករាប់ចំនួនសមាជិកដែលលើកដៃ ។ បើប្រធាននិងលេខាធិការយល់ឃើញថា ការរាប់លទ្ធផលមិនច្បាស់លាស់ទេនោះ ត្រូវបញ្ចេញមតិ និងរាប់សារជាថ្មី ។

<u>ប្រការ ៣៥</u> :

ចំពោះការបញ្ចេញមតិដោយវិធីលើកដៃដែលបានធ្វើពីរដង ហើយនៅតែមិនបានលទ្ធផលច្បាស់លាស់ ព្រឹទ្ធសភាត្រូវប្រើវិធីបោះឆ្នោតជាចំហ ។

វិធីបោះឆ្នោតចំហត្រូវធ្វើដូចតទៅ :

-គណៈកម្មការបោះឆ្នោត កាន់ហិបឆ្នោតដើរប្រមូលយកសន្លឹកឆ្នោតពីសមាជិកព្រឹទ្ធសភា ។ សមាជិកព្រឹទ្ធសភាត្រូវសរសេរឈ្មោះខ្លួនលើសន្លឹកឆ្នោតនោះ ។ សន្លឹកឆ្នោតមានបីយ៉ាង : ពណ៌ខៀវសំគាល់ការមិនព្រម ពណ៌សសំគាល់ការព្រម និងពណ៌សឆ្នូតខៀវសំគាល់អនុប្បវាទ ។

-ក្រោយពីបោះឆ្នោតរួចស្រេចហើយ លេខាធិការត្រូវរាប់សន្លឹកឆ្នោត ។ លុះរាប់សន្លឹកឆ្នោតរួចហើយ ប្រធានព្រឹទ្ធសភាប្រកាសលទ្ធផលជូនអង្គប្រជុំ ។

ប្រការ ៣៦ :

វិធីបោះឆ្នោតចំហនៅវេទិកាប្រព្រឹត្តទៅដូចតទៅ :

-សមាជិកព្រឹទ្ធសភាម្នាក់ៗដើរយកសន្លឹកឆ្នោតមកដាក់ក្នុងហិបដែលនៅលើវេទិកា

-ព្រឹទ្ធសភាប្រើវិធីនេះបាន លុះត្រាតែមានសមាជិកព្រឹទ្ធសភា៦នាក់យ៉ាងតិចស្នើសុំ ។

ប្រការ ៣៧ :

វិធីបោះឆ្នោតសម្ងាត់ត្រូវតែប្រើក្នុងការជ្រើសតាំង ការសំដែងការទុកចិត្ត និងការអនុម័តញត្តិបន្ទោស ។

ប្រការ ៣៨ :

ការអនុម័តទាំងឡាយត្រូវយកតាមមតិភាគច្រើនដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ។ ក្រៅពីនេះ មតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូលត្រូវទុកជាបានការ ។

ប្រការ ៣៩ :

បើចំនួនមតិយល់ព្រម និងចំនួនមតិមិនយល់ព្រមស្មើគ្នា ការបោះឆ្នោតត្រូវធ្វើម្តងទៀត ។ បើលទ្ធផលនៃការបោះឆ្នោតលើកទី២នៅតែស្មើគ្នា ព្រឹទ្ធសភាត្រូវចាត់ទុកថាជាការមិនយល់ព្រម ។

ប្រការ ៤០ :

ក្រោយពីបានឃើញលទ្ធផលនៃការបញ្ចេញមតិរួចហើយ ប្រធានព្រឹទ្ធសភាប្រកាសថាព្រឹទ្ធសភាបានអនុម័តយល់ព្រមហើយ ឬថាព្រឹទ្ធសភាបានអនុម័តមិនយល់ព្រមទេ ។

# ជំពូកទី ១០
## អំពីការប្រកាសការប្រញាប់

### ប្រការ ៤១ :

សេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ការលើកបញ្ហានានា ឬញត្តិណាមួយដែលត្រូវបានប្រកាសជាការប្រញាប់ ត្រូវចុះក្នុងរបៀបវារៈពិភាក្សាមុនគេ ។

### ប្រការ ៤២ :

ការប្រញាប់នេះអាចស្នើសុំឡើងដោយរដ្ឋសភា ដោយរាជរដ្ឋាភិបាល ដោយម្ចាស់សេចក្តីស្នើច្បាប់ ដោយអ្នកលើកបញ្ហាផ្សេងៗ ឬដោយម្ចាស់ញត្តិ ។

ព្រឹទ្ធសភាត្រូវសំរេចលើពាក្យសុំដែលមានចែងក្នុងប្រការខាងលើ ។

### ប្រការ ៤៣ :

អ្នកសុំអោយប្រកាសទុកជាការប្រញាប់ត្រូវជូនហេតុផលជាលាយលក្ខណ៍អក្សរ ។ ប្រធានព្រឹទ្ធសភានាំសេចក្តីទៅថ្លែងជំរាបព្រឹទ្ធសភា ហើយព្រឹទ្ធសភាសំរេចថាយល់ព្រម ឬមិនយល់ព្រមទុកជាការប្រញាប់ ។

## ជំពូកទី ១១
## អំពីរបៀបប្រជុំ

**ប្រការ ៤៤ :**

កូរ៉ុមសំរាប់ប្រជុំពេញអង្គត្រូវមានសមាជិកព្រឹទ្ធសភាច្រាំពីរភាគដប់នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

សមាជិកដែលអវត្តមានត្រូវបានចុះក្នុងបញ្ជីអវត្តមាន ។ បញ្ជីនេះត្រូវបានប្រកាសដោយប្រធាន ដោយបញ្ជាក់អំពីមូលហេតុផង ។

បើកូរ៉ុមមិនគ្រប់ក្នុងរយៈពេល៣០នាទី ក្រោយកាលកំណត់ចាប់ផ្ដើម ប្រធានព្រឹទ្ធសភាត្រូវផ្អាកការប្រជុំ។

**ប្រការ ៤៥ :**

អាសនានុក្រមនៃសមាជិកព្រឹទ្ធសភាសាមញ្ញ ត្រូវរៀបតាមលំដាប់អាយុ ។

**ប្រការ ៤៦ :**

ការកំណត់ថ្ងៃប្រជុំត្រូវធ្វើជាលិខិតផ្ញើទៅជូនសមាជិកព្រឹទ្ធសភា ។ បើមានការកំណត់ដោយផ្ទាល់មាត់ក្នុងពេលប្រជុំ ការកំណត់នេះត្រូវធ្វើជាលិខិតជូនទៅសមាជិកព្រឹទ្ធសភាដែលមិនបានមកប្រជុំ ។

តាមធម្មតា ពេលប្រជុំត្រូវកំណត់យ៉ាងតិច ២ ថ្ងៃមុន វៀរលែងតែក្នុងការប្រញាប់ ។

**ប្រការ ៤៧ :**

លិខិតអញ្ជើញ ត្រូវមានភ្ជាប់ទៅជាមួយនូវរបៀបវារៈប្រជុំ វៀរលែងតែក្នុងការប្រញាប់។

**ប្រការ ៤៨ :**

ក្នុងពេលប្រជុំណាមួយ បើប្រធាននិងអនុប្រធានព្រឹទ្ធសភាមិននៅ ដោយមានហេតុការណ៍អ្វីជាពិសេស ព្រឹទ្ធសភាអាចជ្រើសតាំងប្រធានបណ្ដោះអាសន្នមួយរូបអោយដឹកនាំការប្រជុំបន្ត ។

ប្រការ ៤៩ :

បើមានបញ្ហាត្រូវថ្លែងជំរាបព្រឹទ្ធសភា ប្រធានត្រូវថ្លែងមុនចាប់ផ្តើមរបៀបវារៈ ។

ប្រការ ៥០ :

តាមធម្មតា ដំណើរការត្រូវធ្វើតាមរបៀបវារៈ វៀរលែងតែក្នុងពេលប្រជុំខ្លះដែលអង្គប្រជុំសំរេចផ្សេងពីនេះ ។

មុនចាប់ផ្តើមសម័យប្រជុំ ព្រឹទ្ធសភាអនុម័តរបៀបវារៈ និងសមាសភាពលេខាធិការសម័យប្រជុំ ។

ប្រការ ៥១ :

បើប្រធានយល់ឃើញថាជាការមានប្រយោជន៍ ឬជាការចាំបាច់ ឬបើមានសមាជិកព្រឹទ្ធសភា៦នាក់យ៉ាងតិចស្នើសុំ ប្រធានអាចលើកពេលប្រជុំបាន ។

ប្រការ ៥២ :

សមាជិកទាំងឡាយនៃព្រឹទ្ធសភាត្រូវសុំ ហើយបានទទួលសេចក្តីអនុញ្ញាតពីប្រធានជាមុនសិន ទើបនិយាយបាន ។

ប្រការ ៥៣ :

តាមធម្មតា លេខាធិការត្រូវកត់ឈ្មោះសមាជិកព្រឹទ្ធសភាដែលសុំនិយាយតាមលំដាប់មុនក្រោយ ។

ប្រការ ៥៤ :

ក្នុងការជជែកពិភាក្សា ភាគីនត្រូវនិយាយឆ្លាស់គ្នា អ្នកគាំទ្រនិយាយម្តង អ្នកជំទាស់និយាយម្តង ។

ប្រការ ៥៥ :

តាមគោលការណ៍ រយៈពេលនិយាយសំរាប់សមាជិកព្រឹទ្ធសភាម្នាក់ៗត្រូវមានកំណត់។ សមាជិកព្រឹទ្ធសភាដែលអនុញ្ញាតអោយនិយាយ ត្រូវនិយាយតែរឿងដែលកំពុងពិភាក្សា ។ បើនិយាយចាកប្រធាន ប្រធានព្រឹទ្ធសភាត្រូវរំលឹកអោយធ្វើតាមរបៀបវារៈខាងលើ ។

ប្រការ ៥៦ :

តាមធម្មតា សមាជិកព្រឹទ្ធសភាដែលបានចុះឈ្មោះសុំនិយាយ និយាយបាន ២០ នាទីយ៉ាងយូរ ។ សមាជិកព្រឹទ្ធសភាដែលគ្រាន់តែសុំឆ្លើយតប និយាយបានតែ ៥ នាទីទេ ។

បើប្រធានយល់ឃើញថាជាការចាំបាច់ ឬជាការមានប្រយោជន៍ក្នុងការពិភាក្សានោះ ប្រធានអាចអនុញ្ញាតបន្ថែមពេល១០នាទី ។ ការបន្ថែមនេះអាចអនុញ្ញាតអោយបន្តបាន៣ដងក្នុងរឿងដដែល ។

ប្រការ ៥៧ :

បទបញ្ញត្តិអំពីការចុះឈ្មោះសុំនិយាយជាលំដាប់គ្នា និងអំពីការកំណត់រយៈពេលនិយាយនេះ ប្រើសំរាប់តែសមាជិកព្រឹទ្ធសភា មិនប្រើសំរាប់សមាជិករាជរដ្ឋាភិបាល ឬអ្នកតំណាងទេ ។

ប្រការ ៥៨ :

បើមានការជ្រួលច្របល់ក្នុងពេលប្រជុំ ហើយប្រធានហាមពុំស្តាប់ ប្រធានអាចលើកពេលប្រជុំដោយក្រោកដើរចេញពីសាលប្រជុំ ។

ប្រការ ៥៩ :

ហាមនិយាយកាត់អ្នកដទៃ និយាយវាយប្រហារលើបុគ្គល និងសំដែងអាកាសៈផ្សេងៗដែលនាំអោយខូចសណ្តាប់ធ្នាប់អង្គប្រជុំ ។

## ជំពូកទី ១២
## អំពីការរក្សាសេចក្ដីស្ងប់ក្នុងពេលប្រជុំ

**ប្រការ ៦០ :**

ប្រធានព្រឹទ្ធសភាមានភារកិច្ចរក្សាការពារមិនអោយមានភ័យន្តរាយខាងក្នុងក្ដី ខាងក្រៅក្ដី ដែលអាចកើតមានឡើងដល់ព្រឹទ្ធសភាជាយថាហេតុ ។ ដើម្បីសំរេចភារកិច្ចនេះ ប្រធានព្រឹទ្ធសភាមានសិទ្ធិសុំអន្តរាគមន៍ពីកម្លាំងនគរបាល ឬកម្លាំងកងទ័ព ។

**ប្រការ ៦១ :**

ការថែរក្សាការពារសុវត្ថិភាពព្រឹទ្ធសភា ត្រូវធ្វើឡើងដោយប្រធានព្រឹទ្ធសភាក្នុងនាមព្រឹទ្ធសភា ។ ជាគោលការណ៍ ប្រធានព្រឹទ្ធសភាអាចអនុញ្ញាតអោយសាធារណជនចូលក្នុងសាលប្រជុំតាមចំនួនកន្លែងដែលមាន ។ ប៉ុន្តែបើជនណាធ្វើអោយរង្វៀសដោយវិធីណាមួយដល់អង្គប្រជុំ ប្រធានព្រឹទ្ធសភាអាចបណ្ដេញជននោះចេញភ្លាម ។

**ប្រការ ៦២ :**

កាលបើព្រឹទ្ធសភាសំរេចថាត្រូវប្រជុំជាសម្ងាត់ ប្រធានព្រឹទ្ធសភានិងលេខាធិការត្រូវត្រួតពិនិត្យមើលអោយច្បាស់ជាមុនសិនថាពិតជាគ្មានមនុស្សដទៃក្រៅពីសមាជិកព្រឹទ្ធសភា លេខាធិការ និងឥស្សរជនដែលព្រឹទ្ធសភាត្រូវការចាំបាច់នៅក្នុងសាលប្រជុំ ។

## ជំពូកទី -១៣
## អំពីការខានមកប្រជុំ

<u>ប្រការ ៦៣</u> :

ក្នុងពេលប្រជុំនីមួយៗ លេខាធិការស្រង់ឈ្មោះសមាជិកព្រឹទ្ធសភាដែលអវត្តមាន ដោយបញ្ជាក់មូលហេតុច្បាស់លាស់ ។

<u>ប្រការ ៦៤</u> :

សមាជិកព្រឹទ្ធសភាមិនអាចអវត្តមានដោយមិនមានការអនុញ្ញាតពីប្រធានព្រឹទ្ធសភាបានឡើយ ។

<u>ប្រការ ៦៥</u> :

ប្រធានអាចអនុញ្ញាតអោយសមាជិកព្រឹទ្ធសភាឈប់បានយ៉ាងយូរបំផុត១៥ថ្ងៃ ក្នុងសម័យប្រជុំនីមួយ ។ ។ ការឈប់លើសពី១៥ថ្ងៃ ត្រូវសុំការអនុម័តពីអង្គប្រជុំ ។

<u>ប្រការ ៦៦</u> :

សមាជិកព្រឹទ្ធសភាដែលអវត្តមានដោយមូលហេតុមានជម្ងឺរយៈពេលប្រាំថ្ងៃជាប់ៗ គឺត្រូវមានសំបុត្រពេទ្យយកមកជាសំអាង ។

<u>ប្រការ ៦៧</u> :

សមាជិកព្រឹទ្ធសភាដែលអាក់ខានមកប្រជុំលើសពីបីថ្ងៃដោយគ្មានការអនុញ្ញាត ត្រូវទទួលទណ្ឌកម្មខាងវិន័យ ក្រើនរំលឹក ។

<u>ប្រការ ៦៨</u> :

កាលណាបានទទួលសេចក្តីអញ្ជើញមកប្រជុំតាមបទបញ្ញត្តិនៃប្រការ ៤៦ ហើយសមាជិកព្រឹទ្ធសភាមិនបានមកប្រជុំដោយឥតមានមូលហេតុយកជាការបាន សមាជិកព្រឹទ្ធសភានោះត្រូវទទួលទណ្ឌកម្មខាងវិន័យដូចខាងក្រោម :

ក-ការខានមកប្រជុំចំនួនបីថ្ងៃត្រូវទទួលការក្រើនរំលឹក

ខ-បើទទួលការក្រើនរំលឹកហើយ ហើយនៅតែមិនចូលមកប្រជុំ ត្រូវទទួលការក្រើនរំលឹកដោយចុះក្នុងកំណត់ហេតុ ។

គ-បើបានទទួលដំណឹងរំលឹកក្រោយនេះហើយ ហើយនៅតែមិនចូលប្រជុំឬមិនផ្តល់មូលហេតុច្បាស់លាស់ ត្រូវទទួលការបន្ទោសជាលាយលក្ខណ៍អក្សរ ។ ទណ្ឌកម្មខាងវិន័យនេះត្រូវប្រគល់ដល់ទីលំនៅរបស់សាមីខ្លួន ។

ឃ-បើបានទទួលទណ្ឌកម្មខាងវិន័យតាមលំដាប់ទាំង៣យ៉ាងខាងលើនេះ ហើយក្នុងរវាងមួយខែក្រោយមក សមាជិកព្រឹទ្ធសភាដែលនៅតែប្រព្រឹត្តខុសទៀត ត្រូវធ្វើទណ្ឌកម្មខាងវិន័យជាទម្ងន់ ដោយបន្ទោសជាលាយលក្ខណ៍អក្សរ ហើយប្រកាសផ្សាយដល់មហាជននៅក្នុងប្រភពចាត់តាំង ឬប្រភពជ្រើសតាំងរបស់សមាជិកព្រឹទ្ធសភាដែលបានប្រព្រឹត្តខុស ។

គណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភា ជាអ្នកដាក់ទណ្ឌកម្មខាងវិន័យដោយស្វ័យប្រវត្តិ កាលបើបានដឹងច្បាស់ថា មូលហេតុដែលខានមកប្រជុំនោះមិនអាចយកជាការបាន វៀរលែងតែក្នុងករណីដែលព្រឹទ្ធសភាបានទទួលពាក្យតវ៉ាសមហេតុសមផលពីសាមីខ្លួនក្នុងពេលប្រជុំពេញអង្គ ។

## ជំពូកទី ១៤
## វិធានវិន័យក្នុងពេលប្រជុំ

ប្រការ ៦៩ :

ទណ្ឌកម្មខាងវិន័យដែលយកមកប្រើចំពោះសមាជិកព្រឹទ្ធសភាមានដូចតទៅ :

ក-ក្រើនរំលឹក

ខ-ក្រើនរំលឹកដោយចុះក្នុងកំណត់ហេតុ

គ-បន្ទោសជាលាយលក្ខណ៍អក្សរ

ឃ-បន្ទោសជាលាយលក្ខណ៍អក្សរ ហើយបណ្តេញចេញមួយរយៈពេលពីសាលប្រជុំ ។

ប្រការ ៧០ :

ប្រធានព្រឹទ្ធសភា ត្រូវក្រើនរំលឹកវាគ្មិនណាដែលប្រព្រឹត្តខុស ឬសមាជិកព្រឹទ្ធសភាណាដែលធ្វើអោយខូចសណ្តាប់ធ្នាប់ដោយល្មើសនឹងបទបញ្ញត្តិប្រការ៥៩នៃបទបញ្ជាផ្ទៃក្នុង ។

ប្រការ ៧១ :

សមាជិកព្រឹទ្ធសភាណា ដែលត្រូវក្រើនរំលឹកមួយដងហើយ ហើយនៅតែប្រព្រឹត្តខុសដដែលទៀត នៅក្នុងពេលប្រជុំតែមួយនោះ ប្រធានព្រឹទ្ធសភាត្រូវក្រើនរំលឹកម្តងទៀត ដោយចុះសេចក្តីក្រើនរំលឹកនោះទុកក្នុងកំណត់ហេតុនៃអង្គប្រជុំ ។

ប្រការ ៧២ :

សមាជិកព្រឹទ្ធសភា ដែលត្រូវទទួលការបន្ទោសជាលាយលក្ខណ៍អក្សរនោះគឺ :

ក-សមាជិកព្រឹទ្ធសភាណា ដែលប្រធានបានក្រើនរំលឹក ព្រមទាំងចុះសេចក្តីក្នុងកំណត់ហេតុហើយ ហើយនៅតែមិនរាងចាល

ខ-សមាជិកព្រឹទ្ធសភាណា ដែលត្រូវបានក្រើនរំលឹកបីដងហើយ ហើយនៅតែធ្វើខុសដដែលក្នុងវេលា ៣០ ថ្ងៃ

គ-សមាជិកព្រឹទ្ធសភាណា ដែលនាំអាទិ៍អោយមានការជ្រួលច្របល់ក្នុងសាលប្រជុំ ឬនាំអាទិ៍សមាជិកព្រឹទ្ធសភាច្រើនគ្នា កុំអោយធ្វើការក្នុងព្រឹទ្ធសភា

ឃ-សមាជិកព្រឹទ្ធសភាណា ដែលជេរប្រមាថមើលងាយ ឬបង្កជម្លោះ ឬគំរាមកំហែង សមាជិកព្រឹទ្ធសភាឯទៀត ។

ប្រការ ៧៣ :

សមាជិកព្រឹទ្ធសភាដែលត្រូវទទួលការបន្ទោសជាលាយលក្ខណ៍អក្សរ ហើយបណ្តេញចេញមួយរយៈពេល ពីអង្គប្រជុំគឺ :

ក- សមាជិកព្រឹទ្ធសភាណា ដែលត្រូវទទួលការបន្ទោស ហើយនៅតែមិនរាងចាល

ខ- សមាជិកព្រឹទ្ធសភាណា ដែលញុះញង់អោយប្រើហិង្សា

គ- សមាជិកព្រឹទ្ធសភាណា ដែលជេរប្រមាថមើលងាយព្រឹទ្ធសភា ឬប្រធានព្រឹទ្ធសភា

ឃ- សមាជិកព្រឹទ្ធសភាណា ដែលប្រព្រឹត្តខុស ដោយប្រមាថមើលងាយព្រះមហាក្សត្រ ។

ប្រការ ៧៤ :

ការបន្ទោសជាលាយលក្ខណ៍អក្សរ ឬការបន្ទោសជាលាយលក្ខណ៍អក្សរហើយបណ្តេញចេញផង ត្រូវអនុម័តដោយព្រឹទ្ធសភា តាមវិធីបោះឆ្នោតជាសម្ងាត់ដោយមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល តាមសេចក្តីស្នើពីប្រធានព្រឹទ្ធសភា ។

ប្រការ ៧៥ :

ការបន្ទោសជាលាយលក្ខណ៍អក្សរត្រូវប្រកាសផ្សាយជាសាធារណៈនូវសំរង់កំណត់ហេតុបន្ទោសព្រមទាំងយកទៅបោះពុម្ពហើយបិទនៅក្នុងប្រភពចាត់តាំង ឬប្រភពជ្រើសតាំងរបស់សមាជិកព្រឹទ្ធសភាដែលមានកំហុស ។

ប្រការ ៧៦ :

ការបន្ទោសជាលាយលក្ខណ៍អក្សរហើយបណ្តេញផង ត្រូវទទួលទណ្ឌកម្មដូចតទៅ :

ក-ប្រកាសផ្សាយជាសាធារណៈនូវសំរង់កំណត់ហេតុបន្ទោស ព្រមទាំងយកទៅបោះពុម្ពហើយបិទនៅក្នុងប្រភពចាត់តាំង ឬប្រភពជ្រើសតាំងរបស់សមាជិកព្រឹទ្ធសភាដែលមានកំហុស

ខ-ហាមចូលធ្វើការក្នុងព្រឹទ្ធសភាអស់រយៈ១៥ពេលប្រជុំពេញបន្តបន្ទាប់ ។

## ជំពូកទី ១៥

## អំពីការសុំកែប្រែបទបញ្ញាផ្ទៃក្នុង នៃព្រឹទ្ធសភា

<u>ប្រការ ៧៧</u> :

បទបញ្ញាផ្ទៃក្នុងនេះនឹងទទួលការកែប្រែបានលុះត្រាតែមានសេចក្ដីស្នើសុំពីសមាជិកព្រឹទ្ធសភាមួយភាគបួនយ៉ាងតិចនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ហើយត្រូវមានការអនុម័តយល់ព្រម ដោយសំឡេងភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

## ជំពូកទី ១៦
## អន្តរប្បញ្ញត្តិ

**ប្រការ ៧៨ :**

អាសនៈរបស់សមាជិកព្រឹទ្ធសភាដែលនៅទំនេរ ដោយសុំលាលែង ដោយបោះបង់ចោលការងារចំនួន៣ខែ គ្មានការអនុញ្ញាត ឬដោយទទួលមរណភាព ត្រូវបំពេញជំនួសដោយចាត់តាំង ឬជ្រើសតាំងសមាជិកព្រឹទ្ធសភាថ្មីចេញពីប្រភពដើម ដែលមានអាសនៈទំនេរនោះ ។

**ប្រការ ៧៩ :**

សំរាប់នីតិកាលទី១នេះ បុគ្គលិកនៃអគ្គលេខាធិការដ្ឋានទាំងអស់ត្រូវតែងតាំង ដោយប្រធានព្រឹទ្ធសភាក្រោយពីមានការឯកភាពពីអនុប្រធានទាំងពីរតាមសេចក្តីស្នើរបស់អគ្គលេខាធិការ ។

**ប្រការ ៨០ :**

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូងនៃនីតិកាលទី១ក្នុងរយៈពេល១០ថ្ងៃយ៉ាងយូរ ក្រោយពីមានព្រះរាជក្រឹត្យតែងតាំងសមាជិកទាំងមូលតាមការកោះប្រជុំរបស់ប្រធានព្រឹទ្ធសភាដែលបានទទួលការតែងតាំងពីព្រះមហាក្សត្រ ។

ការបើកសម័យប្រជុំលើកទី ១ នីតិកាលទី ១ កាលពីថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៩ ទុកជាបានការ ។

---

បទបញ្ជាផ្ទៃក្នុងនេះ ត្រូវបានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័ត នៅថ្ងៃទី ៩ ខែ មេសា ឆ្នាំ ១៩៩៩ នាសម័យប្រជុំលើកទី១ នីតិកាលទី១ ។

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ១៩៩៩

ប្រធានព្រឹទ្ធសភា

ជា ស៊ីម